00858137

E239/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 11 / 2012
ម៉ោង (Time/Heure) : 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អនុស្សរណៈ-អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១២

សាធារណៈ / Public

**ជូនចំពោះ:** មេធាវីការពារជនជាប់ចោទ អៀង សារី, សហព្រះរាជអាជ្ញា, សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, សាស្ត្រាចារ្យ A John CAMBPELL, វេជ្ជបណ្ឌិត ឡោ វណ្ណថារី

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រម,មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង និងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ

**កម្មវត្ថុ:** ការជ្រើសរើសអ្នកជំនាញវេជ្ជសាស្ត្រ (វេជ្ជបណ្ឌិត ឡោ វណ្ណថារី)

បន្ថែមពីលើឯកសារ E238 និងឯកសារ E239 អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូងថាវេជ្ជបណ្ឌិត ឡោ វណ្ណថារី ពុំមានឱកាសដើម្បីពិនិត្យ និងវាយតម្លៃសុខភាពរបស់លោក អៀង សារី បានឡើយ (*សូមមើល* ឯកសារ E240.1) ។ ជាងនេះទៀត អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ពុំមានលទ្ធភាពដើម្បីស្វែងរកវេជ្ជបណ្ឌិតកម្ពុជាមួយរូបផ្សេងទៀតសម្រាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងតែងតាំងបានឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះបានសម្រេចបន្ត ការវាយតម្លៃបឋមអំពី សុខភាពរបស់លោក អៀង សារី ជាមួយសាស្ត្រាចារ្យ Campbell ក្នុងនាមជាអ្នកជំនាញវេជ្ជសាស្ត្រតែម្នាក់គត់ដែលតុលាការបានតែងតាំង។ សាស្ត្រាចារ្យ Campbell នឹងពិគ្រោះជាមួយគ្រូពេទ្យព្យាបាល និងអ្នកជំនាញនានានៅឯមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលជាការចាំបាច់ដើម្បីបញ្ចប់ការវាយតម្លៃរបស់គាត់ឱ្យបានពេញលេញ ហើយគាត់នឹងផ្តល់សក្ខីកម្មនៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ខាងមុខនេះ។